ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
លេខ៖ ២៣០៤/២០២៥ កបទ.សអ

សេចក្តីប្រកាសព័ត៌មាន

# ជំនួបសម្តែងការគួរសមរវាង ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងលោក Benoît GUIDÉE ប្រធាននាយកដ្ឋានអាស៊ី និងអូសេអានី នៃក្រសួងអឺរ៉ុប និងការបរទេស នៃសាធារណរដ្ឋបារាំង

នៅព្រឹកថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០២៥ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ បានទទួលជំនួបសម្តែងការគួរសមរបស់លោក **Benoît GUIDÉE** ប្រធាននាយកដ្ឋានអាស៊ី និងអូសេអានី នៃក្រសួងអឺរ៉ុប និងការបរទេសនៃសាធារណរដ្ឋបារាំង ដែលបានអញ្ជើញមកកម្ពុជា ដើម្បីធ្វើជាសហប្រធាននៃកិច្ចប្រជុំពិគ្រោះយោបល់នយោបាយទ្វេភាគីកម្ពុជា-បារាំង លើកទី៣។

នៅក្នុងជំនួបសម្តែងការគួរសមនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានកោតសរសើរចំពោះកិច្ចពិភាក្សាប្រកបដោយផ្លែផ្កាដែលបានធ្វើឡើងមុននេះ ក្នុងកិច្ចពិគ្រោះយោបល់នយោបាយទ្វេភាគីលើកទី៣ ដែលបានឆ្លុះបញ្ចាំងពីភាពរឹងមាំនៃកិច្ចសន្ទនាកម្ពុជា-បារាំង និងការប្តេជ្ញាចិត្តរួមគ្នារបស់ភាគីទាំងពីរក្នុងការលើកកម្ពស់ទំនាក់ទំនងភាពជាដៃគូប្រវត្តិសាស្ត្រឱ្យឈានដល់កម្រិតថ្មី។

ភាគីទាំងពីរបានស្វាគមន៍ចំពោះសម្ទុះជាវិជ្ជមានក្នុងទំនាក់ទំនងទ្វេភាគី ដែលបានឆ្លុះបញ្ចាំងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចកម្រិតខ្ពស់រវាងប្រទេសទាំងពីរនាពេលកន្លងមក និងទៅអនាគត ការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូល Francophonie លើកទី២០ នៅខេត្តសៀមរាប ក្នុងខែវិច្ឆិកា ឆ្នាំ២០២៦ និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាក្នុងការលើកកម្ពស់ទំនាក់ទំនងទ្វេភាគី ឆ្ពោះទៅសម្រេចឱ្យបាននូវភាពជាដៃគូយុទ្ធសាស្ត្រដែលមាននិរន្តរភាព នៅក្នុងឆ្នាំ២០២៦ ដែលជាឆ្នាំដ៏សំខាន់សម្រាប់ទំនាក់ទំនងកម្ពុជា-បារាំង។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់អំពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជាក្នុងការចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិចាប់តាំងពីឆ្នាំ២០០៦មក។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណផងដែរចំពោះតួនាទីសំខាន់របស់ប្រទេសបារាំងក្នុងដំណើរការឈានទៅសម្រេចបាននូវកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ ក៏ដូចជាការគាំទ្រជាបន្តបន្ទាប់របស់

ប្រទេសបារាំង ជាពិសេសចំពោះជម្លោះព្រំដែនកម្ពុជា-ថៃដែលកំពុងកើតឡើង។ ក្នុងស្មារតីសាមគ្គីភាពជាមួយកម្ពុជា **លោក** Benoît GUIDÉE បានចូលរួមរំលែកទុក្ខ និងសម្តែងការអាណិតអាសូរយ៉ាងក្រៃលែងចំពោះប្រជាជនកម្ពុជាដែលបានបាត់បង់ជីវិត និងជនភៀសសឹកដែលរងគ្រោះដោយជម្លោះព្រំដែនកម្ពុជា-ថៃ។

ក្នុងវិស័យសេដ្ឋកិច្ច **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រចំពោះការគាំទ្រដ៏យូរអង្វែងរបស់ប្រទេសបារាំង ជាពិសេសតាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (AFD)។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ដែលបារាំងជាប្រភពទេសចរណ៍អឺរ៉ុបឈានមុខគេរបស់កម្ពុជា និងជាដៃគូពាណិជ្ជកម្មអឺរ៉ុបដ៏សំខាន់មួយ។ ទន្ទឹមនឹងនេះដែរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តដល់ការវិនិយោគរបស់បារាំងបន្ថែមទៀតនៅក្នុងប្រទេសកម្ពុជា ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន។

នៅក្នុងកិច្ចសហប្រតិបត្តិការផ្នែកបេតិកភណ្ឌវប្បធម៌ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់បារាំង ចំពោះការរួមចំណែកដ៏យូរអង្វែងក្នុងការអភិរក្សសម្បត្តិបេតិកភណ្ឌវប្បធម៌របស់កម្ពុជា ដែលបច្ចុប្បន្នបាននិងកំពុងទទួលរងការបំផ្លិចបំផ្លាញ។ ក្នុងន័យនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអំពាវនាវឱ្យប្រទេសបារាំង ក្នុងនាមជាប្រទេសឈានមុខគេក្នុងវិស័យអភិរក្សបេតិកភណ្ឌវប្បធម៌ បន្តប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាក្នុងការការពារបេតិកភណ្ឌវប្បធម៌របស់ខ្លួនជាពិសេសក្នុងកាលៈទេសៈនៃជម្លោះព្រំដែនកម្ពុជា-ថៃ។

នៅចុងបញ្ចប់នៃកិច្ចសន្ទនា **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់កម្ពុជា ក្នុងការពង្រឹងមិត្តភាព និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយបារាំងបន្ថែមទៀត ទាំងក្នុងក្របខណ្ឌទ្វេភាគី តំបន់ និងពហុភាគី ហើយបានបញ្ជាក់ពីការត្រៀមខ្លួនជាស្រេចរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសហការយ៉ាងជិតស្និទ្ធជាមួយប្រទេសបារាំង ដើម្បីលើកកម្ពស់ភាពជាដៃគូដ៏រឹងមាំរវាងប្រទេសទាំងពីរ។

បន្ទាប់ពីជំនួបសម្តែងគួរសមខាងលើ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ បានចូលរួមជាអធិបតីក្នុងពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងសាធារណរដ្ឋបារាំង ស្តីពីកម្មវិធីស្ម័គ្រចិត្តអន្តរជាតិ សម្រាប់ការបម្លាស់ប្តូរ និងសាមគ្គីភាព និងសកម្មភាព France Volontaires នៅកម្ពុជា ដែលបានចុះហត្ថលេខាដោយ **ឯកឧត្តម ស៊ុន សុវណ្ណា** រដ្ឋលេខាធិការនៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និង**ឯកឧត្តម** Oliver RICHARD ឯកអគ្គរដ្ឋទូតបារាំងប្រចាំកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៥